# ក្រមសីលធម៌សំរាប់ មន្ត្រីប្រតិបត្តិច្បាប់

# CODE OF CONDUCT FOR LAW ENFORCEMENT OFFICIALS

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

# ក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់

# Code of Conduct for Law Enforcement Officials

*ត្រូវបានអនុម័តដោយសេចក្តីសំរេចរបស់មហាសន្និបាត*

*អង្គការសហប្រជាជាតិ លេខ៣៤/១៦៩ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៩*

## មាត្រា ១

ក្នុងការបំរើសហគមន៍ និងក្នុងការការពារមនុស្សគ្រប់រូបកុំឱ្យប្រព្រឹត្តខុសច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវបំពេញភារកិច្ចរបស់ខ្លួន ឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់គ្រប់ពេលវេលា ដោយមានការទទួលខុសត្រូវខ្ពស់តាមវិជ្ជាជីវៈរបស់ខ្លួន ។

***អត្ថាធិប្បាយ :***

ក-ពាក្យថា "មន្ត្រីប្រតិបត្តិច្បាប់" សំដៅដល់មន្ត្រីច្បាប់ទាំងអស់ ទោះជាត្រូវតែងតាំង ឬត្រូវបានជ្រើសតាំង

ក្តី ដែលប្រើប្រាស់អំណាចនគរបាល ជាពិសេសអំណាចក្នុង-ការចាប់ខ្លួន ឬឃុំខ្លួន ។

ខ- នៅក្នុងប្រទេសទាំងឡាយ ដែលអាជ្ញាធរយោធាប្រើប្រាស់អំណាចនគរបាល ទោះជាមាន ឬគ្មានឯកសណ្ឋានក្តី ឬដោយកំលាំងសន្តិសុខរបស់រដ្ឋក្តី មន្ត្រីទាំងឡាយ ដែលបំរើការងារនោះត្រូវចាត់ចូលក្នុងនិយមន័យនៃមន្ត្រីប្រតិបត្តិច្បាប់ ។

គ- ការផ្តល់សេវាបំរើសហគមន៍ គឺមានគោលដៅដាក់បញ្ចូលជាពិសេស នូវការផ្តល់សេវាជំនួយឧបត្ថម្ភដល់សមាជិកសហគមន៍ទាំងនោះ ហើយដោយសារតែមូលហេតុផ្ទាល់ខ្លួន មូលហេតុសេដ្ឋកិច្ច សង្គមកិច្ច ឬភាពបន្ទាន់បង្ខំផ្សេងទៀត ទើបពួកគេត្រូវការជំនួយទាំងនេះភ្លាមៗ ។

ឃ- បញ្ញត្តិនេះមានគោលដៅគ្របដណ្តប់ មិនត្រឹមតែអំពើទាំងអស់ដែលហឹង្សា សាហាវព្រៃផ្សៃ និងគ្រោះ

ផ្ទាក់ដល់អ្នកដទៃប៉ុណ្ណោះទេ តែថែមទាំងមានវិសាលភាព ដល់ការហាមឃាត់ទាំងស្រុង ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ។ បញ្ញត្តិនេះក៏អនុវត្តចំពោះជនទាំងឡាយដែលមិនអាចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌផងដែរ ។

## មាត្រា ២

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងរក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់មនុស្សគ្រប់រូប ។

## អត្ថាធិប្បាយ :

ក- សិទ្ធិមនុស្សដូចមានចែងខាងលើត្រូវបានកំណត់ និងការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ ក្នុង-ចំណោមលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធ មានសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីប្រកាសស្តីពីការ

ការពារជនគ្រប់រូបពីការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការលប់បំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការលប់បំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបនិងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មអាប៉ាថេដ អនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់ការគ្រប់គ្រងអ្នកទោស និងអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ។

ខ-សេចក្តីអត្ថាធិប្បាយជាតិលើបញ្ញត្តិនេះ គួរចង្អុលបង្ហាញពីបទបញ្ញត្តិជាតិ ឬតំបន់ ដែលបានកំណត់ និងការពារសិទ្ធិទាំងនេះ ។

## មាត្រា ៣

មន្ត្រីប្រតិបត្តិច្បាប់ អាចប្រើប្រាស់កំលាំងបានតែក្នុងករណីណាដែលចាំបាច់បំផុត និងស្ថិតក្នុងវិសាលភាពតម្រូវសំរាប់តែការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ។

***អត្ថាធិប្បាយ :***

ក- បញ្ញត្តិនេះបញ្ជាក់ថា ការប្រើប្រាស់កំលាំងដោយមន្ត្រីប្រតិបត្តិច្បាប់ គួរតែជាករណីលើកលែង។ នេះមានន័យថា មន្ត្រីប្រតិបត្តិច្បាប់អាចត្រូវបានអនុញ្ញាតិឱ្យប្រើកំលាំងបាន តែក្នុងកាលៈទេសៈចាំបាច់សមហេតុផលដើម្បីទប់ស្កាត់បទល្មើស ឬដើម្បីធ្វើឱ្យមានប្រសិទ្ធភាព ឬដើម្បីជួយដល់ការចាប់ខ្លួនជនល្មើសឬជនសង្ស័យតាមច្បាប់ ដោយគ្មានការប្រើកំលាំងណាមួយហួសពីនេះ ត្រូវបានអនុញ្ញាតឱ្យប្រើនោះទេ។

ខ- តាមធម្មតា ច្បាប់ជាតិដាក់កំហិតយ៉ាងតឹងរឹង ដល់មន្ត្រីប្រតិបត្តិច្បាប់ ក្នុងការប្រើប្រាស់កំលាំង ស្របតាមគោលការណ៍សមាមាត្រ ។ នេះក៏ជាប្រការត្រូវយល់ថា គោលការណ៍ជាតិនៃសមាមាត្រនេះ ត្រូវតែគោរពតាមក្នុងការបកស្រាយបញ្ញត្តិនេះ ។ គ្មានករណីណាមួយដែលបញ្ញត្តិនេះ ត្រូវបានបកស្រាយ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់កំលាំងដែលមិនសមាមាត្រ ដើម្បីសំរេចបាននូវគោលដៅស្របច្បាប់ណាមួយនោះទេ។

គ-ការប្រើប្រាស់អាវុធត្រូវបានចាត់ទុកថាជាវិធានការមួយហួសហេតុ។ មន្ត្រីប្រតិបត្តិច្បាប់ គួរប្រើគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដោយជៀសវាងមិនប្រើអាវុធ ជាពិសេសទៅលើកុមារ។ ជាទូទៅ ការប្រើអាវុធ ត្រូវហាមឃាត់ លើកលែងតែក្នុងករណីណាដែលជនល្មើសតដៃ ឬបង្កគ្រោះថ្នាក់ដល់ជីវិតអ្នកដទៃ ហើយការចាត់វិធានការនេះមិនបានធ្ងន់ល្មម នឹងបញ្ឈប់ ឬចាប់ខ្លួនជនល្មើសនោះបាន។

ពេលណាដែលមានការបាញ់កាំភ្លើង ត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចភ្លាម ។

## មាត្រា ៤

បញ្ហានានាដែលមានចរិតជាការសំងាត់ ឋិតក្នុងដៃមន្ត្រីប្រតិបត្តិច្បាប់ ត្រូវតែរក្សាជាការសំងាត់ លើកលែងតែមានការតម្រូវយ៉ាងតឹងរឹងក្នុងការបំពេញភារកិច្ច ឬតម្រូវការស្វែងរកយុត្តិធម៌ ប្រសិនបើមិនដូច្នេះ ការសំងាត់នេះមិនអាចទំលាយបានឡើយ ។

***អត្ថាធិប្បាយ :***

តាមចរិកលក្ខណៈនៃការងាររបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ ទទួលព័ត៌មាននានា ដែលអាចទាក់ទងដល់ជីវិតឯកជន ឬដែលអាចប៉ះពាល់យ៉ាងខ្លាំងដល់ផលប្រយោជន៍ និងជាពិសេសដល់កិត្តិយសអ្នកដទៃ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវប្រុងប្រយ័ត្នបំផុតក្នុងការការពារ និងការប្រើប្រាស់ព័ត៌

មាននេះ ហើយព័ត៌មាននេះអាចលាតត្រដាងបាន តែក្នុង-ការបំពេញភារកិច្ច ឬបំរើឱ្យតម្រូវការយុត្តិធម៌តែប៉ុណ្ណោះ។ ការលាតត្រដាងព័ត៌មានបែបនេះ សំរាប់គោលបំណងអ្វីផ្សេងពីនេះ គឺជាការមិនត្រឹមត្រូវទាល់តែសោះ។

## មាត្រា ៥

គ្មានមន្ត្រីប្រតិបត្តិច្បាប់ណាអាចប្រព្រឹត្ត ញុះញង់ ឬបណ្តោយឱ្យមានការធ្វើទារុណកម្ម ឬការប្រព្រឹត្ត ឬដាក់ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬក៏មិនត្រូវយកបទបញ្ជាថ្នាក់លើ ឬកាលៈទេសៈពិសេស ដូចជា ស្ថានភាពមានសង្គ្រាម ឬការគំរាមធ្វើសង្គ្រាម ការគំរាមដល់សន្តិសុខជាតិ អស្ថេរភាពនយោបាយផ្ទៃក្នុង ឬស្ថានភាពគ្រាអាសន្នទូទៅដទៃទៀត មកធ្វើជាយុត្តិកម្មដល់ការធ្វើទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកនោះឡើយ ។

***អត្ថាធិប្បាយ :***

ក- ការហាមប្រាមនេះ ដកចេញពីសេចក្តីប្រកាសជាសកលស្តីពីកិច្ចការពារបុគ្គលគ្រប់រូបពីការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយមានខ្លឹមសារថា "អំពើបែបនេះ គឺជាអំពើល្មើសមួយចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយត្រូវផ្តន្ទាទោសដោយសារថានេះគឺជាការបដិសេធពីគោលបំណងនៃធម្មនុញ្ញសហប្រជាជាតិ ហើយក៏ជាការរំលោភបំពានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀត ។

ខ- សេចក្តីប្រកាសនេះ ឱ្យនិយមន័យនៃពាក្យទារុណកម្ម ដូចខាងក្រោមនេះ :

"...ទារុណកម្ម សំដៅដល់អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ និងការរងទុក្ខយ៉ាងធ្ងន់ធ្ងរ ទោះផ្លូវកាយ ឬផ្លូវចិត្ត ដែលបង្កឡើងដោយចេតនា ឬដោយការញុះញង់របស់មន្ត្រីសាធារណៈ ទៅលើជនណាម្នាក់ ក្នុងគោលបំណងឱ្យជននោះ ឬតតីយជនណាម្នាក់ ផ្តល់ព័ត៌មាន ឬចំលើយសារភាព ការដាក់ទណ្ឌកម្មចំពោះអំពើ ដែលជននោះបានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬធ្វើការបំភិតបំភ័យជននោះ ឬជនដទៃផ្សេងទៀត។ នេះមិនរាប់បញ្ចូលនូវការឈឺចាប់ ឬការរងទុក្ខ ដែលកើតពីការដាក់ទណ្ឌកម្មស្របច្បាប់ក្នុងករិតមួយ ដែលស្របតាមបញ្ញត្តិដែលមានចែងក្នុងបទដ្ឋានអប្បបរមាសំរាប់ការគ្រប់គ្រងអ្នកទោសនោះឡើយ"។

គ- ពាក្យ "ការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប" មហាសន្និបាតអង្គការសហប្រជាជាតិ មិនទាន់បានឱ្យនិយមន័យនៅឡើយទេ ប៉ុន្តែពាក្យនេះគួរតែត្រូវបានបកស្រាយយ៉ាងណា ដើម្បី

ពង្រីកការការពារឱ្យបានទូលាយបំផុតតាមដែលអាចធ្វើបាន ប្រឆាំងនឹងការរំលោភបំពានគ្រប់យ៉ាង មិនថាផ្លូវកាយ ឬ ផ្លូវចិត្តឡើយ ។

## មាត្រា ៦

មន្ត្រីប្រតិបត្តិច្បាប់ត្រូវធានាឱ្យបាននូវការការពារពេញលេញ ដល់សុខភាពរបស់ជនដែលថិតក្នុងការឃុំខ្លួនរបស់ខ្លួន ជាពិសេស ត្រូវចាត់វិធានការភ្លាមៗ ដើម្បីធានាឱ្យមានការយកចិត្តទុកដាក់ដល់សុខភាព តាមការចាំបាច់ ។

***អត្ថាធិប្បាយ :***

ក- "ការយកចិត្តទុកដាក់សុខភាព " សំដៅដល់ការផ្តល់សេវាផ្សេងៗដោយបុគ្គលិកផ្នែកសុខាភិបាល ក្នុងនោះមានគ្រូពេទ្យជំនាញ និងគ្រូពេទ្យជំនួយ ត្រូវតែប្រចាំការជានិច្ច ដើម្បីឆ្លើយតបតាមតម្រូវការ ឬការស្នើសុំ ។

ខ- ប្រសិនបើបុគ្គលិកសុខាភិបាលចាំបាច់ ត្រូវចូល

រួមក្នុងកិច្ចប្រតិបត្តិការជាមួយមន្ត្រីប្រតិបត្តិច្បាប់ នោះមន្ត្រីប្រតិបត្តិច្បាប់ ត្រូវពិចារណាលើការវិនិច្ឆ័យរបស់បុគ្គលិកសុខាភិបាលនេះ នៅពេលដែលពួកគាត់ផ្តល់យោបល់ថាត្រូវផ្តល់ការព្យាបាលឱ្យបានសមរម្យ ដល់ជនដែលនៅក្នុងឃុំតាមរយៈ ឬក្នុងការពិគ្រោះយោបល់ជាមួយបុគ្គលិកសុខាភិបាលដែលមិនថិតក្នុងកិច្ចប្រតិបត្តិការ របស់មន្ត្រីប្រតិបត្តិច្បាប់ ។

គ-មន្ត្រីប្រតិបត្តិច្បាប់ ក៏ត្រូវធានាឱ្យមានការយកចិត្តទុកដាក់សុខភាពដល់ជនរងគ្រោះ ដោយការរំលោភបំពានច្បាប់ ឬដោយឧបទ្ទវហេតុផ្សេងៗ ដែលកើតឡើងក្នុងពេលមានការប្រព្រឹត្តអំពើរំលោភច្បាប់ផងដែរ ។

## មាត្រា ៧

មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវប្រព្រឹត្តអំពើពុករលួយជាដាច់ខាត ហើយត្រូវប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះ ឱ្យបានខ្លាំងក្លា ។

## *អត្ថាធិប្បាយ :*

ក- អំពើពុករលួយ ក៏ដូចជាអំពើដទៃទៀតនៃការបំពានអំណាចដែរ មានវិសមត្ថភាពជាមួយនឹងវិជ្ជាជីវៈជាមន្រ្តីប្រតិបត្តិច្បាប់។ ច្បាប់ត្រូវយកមកអនុវត្តន៍ឱ្យបានពេញលេញចំពោះមន្រ្តីប្រតិបត្តិច្បាប់ដែលប្រព្រឹត្តអំពើពុករលួយ ព្រោះថា រដ្ឋាភិបាលមិនអាចរំពឹងថា យកច្បាប់មកអនុវត្តចំពោះប្រជាពលរដ្ឋរបស់ខ្លួនបានទេ ប្រសិនបើរដ្ឋាភិបាលមិនអាចអនុវត្ត ឬនឹងមិនអនុវត្តន៍ច្បាប់ឱ្យបានត្រឹមត្រូវ ទៅលើភ្នាក់ងារផ្ទាល់របស់ខ្លួន ឬក្នុងក្របខ័ណ្ឌស្ថាប័នខ្លួននោះ។

ខ- ទន្ទឹមនឹងនិយមន័យនៃពាក្យ "ពុករលួយ" ត្រូវតែមានចែងក្នុងច្បាប់ជាតិនោះ ពាក្យនេះក៏ត្រូវយល់ក្នុងន័យមួយគ្របដណ្តប់ផងដែរលើអំពើសកម្ម ឬអកម្មក្នុងការបំពេញភារកិច្ច ឬទាក់ទងនឹងភារកិច្ចណាមួយ ដែលពាក់ព័ន្ធនឹងការទាមទារ ឬទទួលយកអំណោយ ការសន្យា ឬរង្វាន់លើកទឹកចិត្តផ្សេងៗ ឬក៏ការទទួលយកដោយខុសនូវរបស់

ទាំងនេះ នៅពេលអំពើនោះត្រូវបានប្រព្រឹត្តដោយសកម្ម ឬអកម្ម។

គ- ពាក្យថា "អំពើពុករលួយ" ដែលបានចែងក្នុងប្រយោគខាងលើ ក៏ត្រូវយល់ក្នុងន័យមួយ ក្តោបទាំងការប៉ុនប៉ងប្រព្រឹត្តអំពើពុករលួយផងដែរ។

## មាត្រា ៨

មន្ត្រីប្រតិបត្តិច្បាប់ ត្រូវគោរពតាមច្បាប់ និងក្រមសីលធម៌នេះ។ មន្ត្រីប្រតិបត្តិច្បាប់ក៏ត្រូវបង្ការ និងប្រឆាំងយ៉ាងម៉ឺងម៉ាត់ចំពោះអំពើហឹង្សា ឱ្យបានល្អបំផុតតាមសមត្ថភាពរបស់ខ្លួន។

មន្ត្រីប្រតិបត្តិច្បាប់ ដែលមានហេតុផលនឹងជឿថា មានការរំលោភបំពាន ឬប្រុងនឹងរំលោភបំពានលើក្រមនេះ ត្រូវរាយការណ៍អំពីរឿងនេះទៅអាជ្ញាធរថ្នាក់លើរបស់ខ្លួន ហើយប្រសិនជាចាំបាច់ ត្រូវរាយការណ៍ទៅស្ថាប័ន ឬអាជ្ញា

ធរមានសមត្ថកិច្ចដទៃទៀត ដែលមានអំណាចពិនិត្យ ឬដោះស្រាយ។

***អត្ថាធិប្បាយ :***

ក- ក្រមនេះត្រូវបានគោរពប្រតិបត្តិតាម កាលណាក្រមនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ និងការអនុវត្តជាតិ។ ប្រសិនបើច្បាប់ និងការអនុវត្តជាតិមានចែងពីបទបញ្ញត្តិតឹងរឹងជាងបទបញ្ញត្តិនៃក្រមនេះ បទបញ្ញត្តិដែលតឹងរឹងនេះ ត្រូវយកមកប្រតិបត្តិតាម។

ខ- មាត្រានេះ សំដៅរក្សាតុល្យភាពរវាងមួយផ្នែកជាតម្រូវការឱ្យមានបទវិន័យផ្ទៃក្នុងរបស់ស្ថាប័នដែលសុវត្ថិភាពសាធារណៈពឹងអាស្រ័យលើយ៉ាងធំធេង និងមួយផ្នែកទៀតជាតម្រូវការសំរាប់ដោះស្រាយអំពើរំលោភបំពានលើសិទ្ធិមនុស្សជាមូលដ្ឋាន។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវរាយការណ៍ពីការរំលោភបំពាននោះជូនថ្នាក់លើតាមលំដាប់ឋានានុក្រម

ហើយចាត់វិធានការត្រឹមត្រូវតាមច្បាប់ផ្សេងទៀត ដែលនៅក្រៅឋានានុក្រមរបស់ខ្លួន តែនៅពេលណាដែលគ្មានដំណោះស្រាយផ្សេងទៀត ឬដំណោះស្រាយនោះ គ្មានប្រសិទ្ធភាព។ ក្នុងករណីនេះ មន្ត្រីប្រតិបត្តិច្បាប់ មិនត្រូវទទួលរងទណ្ឌកម្មរដ្ឋបាល ឬទោសទណ្ឌផ្សេងទៀត ដោយសារតែខ្លួនបានរាយការណ៍ពីការរំលោភបំពានក្រមនេះ ឬជិតនឹងរំលោភបំពានក្រមនេះ។

គ- ពាក្យ "ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដែលមានអំណាចពិនិត្យ ឬដោះស្រាយ " សំដៅដល់អាជ្ញាធរ ឬស្ថាប័ន ដែលមាននៅក្នុងច្បាប់ជាតិ ទោះជាអាជ្ញាធរ ឬស្ថាប័ននោះស្ថិតនៅក្នុងទីភ្នាក់ងារប្រតិបត្តិច្បាប់ ឬឯករាជ្យក៏ដោយ ឬដោយលក្ខន្តិកៈ ច្បាប់ទំនៀមទំលាប់ ឬការអនុវត្តដទៃទៀត ដើម្បីពិនិត្យលើបណ្ដឹងសារទុក្ខ ឬបណ្ដឹងផ្សេងទៀត ដែលកើតចេញពីការរំលោភបំពាននានានៅក្នុងវិសាលភាពនៃក្រមសីលធម៌នេះ ។

ឃ- នៅប្រទេសខ្លះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អាចត្រូវបានចាត់ទុកថាជាការបំពេញភារកិច្ចពិនិត្យបណ្ដឹង ប្រហាក់ប្រហែលគ្នាទៅនឹងភារកិច្ច ដែលបានរៀបរាប់នៅក្នុងកថាខ័ណ្ឌ(គ)ខាងលើ។ ហេតុដូច្នេះ មន្ត្រីប្រតិបត្តិច្បាប់ អាចយកការរំលោភបំពាននេះ ទៅផ្សព្វផ្សាយដល់សាធារណៈជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបាន ប្រសិនបើគាត់ អាចបង្ហាញមូលហេតុថា នេះជាវិធានការចុងក្រោយ និង ស្របទៅតាមច្បាប់ និងទំនៀមទម្លាប់របស់ប្រទេស និង គោរពតាមបញ្ញត្តិនៃមាត្រាទី៤ នៃក្រមសីលធម៌នេះ ។

ង- មន្ត្រីប្រតិបត្តិច្បាប់ ដែលអនុវត្តតាមបញ្ញត្តិនៃ ក្រមសីលធម៌នេះ សក្តិសមនឹងទទួលបាននូវការគោរព ការគាំទ្រយ៉ាងពេញទំហឹង ព្រមទាំងកិច្ចសហប្រតិបត្តិការពីសហគមន៍ និងស្ថាប័នរបស់ខ្លួន ព្រមទាំងពីមន្ត្រីប្រតិបត្តិច្បាប់អាជីពផ្សេងទៀត។

~~~~~~~~~
~~~~~~~~~

# Code of Conduct for Law Enforcement Officials

*Adopted by General Assembly resolution 34/169 of 17 December 1979*

## Article 1

Law enforcement officials shall at all times fulfill the duty imposed upon them by law, by serving the community and by protecting all persons against illegal acts, consistent with the high degree of responsibility required by their profession.

**Commentary :**

(a) The term "law enforcement officials", includes all officers of the law, whether appointed or elected, who exercise police powers, especially the powers of arrest or detention.

(b) In countries where police powers are exercised by military authorities, whether uniformed or not, or by State security forces, the definition of law enforcement officials shall be regarded as including officers of such services.

(c) Service to the community is intended to include particularly the rendition of services of assistance to those members of the community who by reason of personal, economic, social or other emergencies are in need of immediate aid.

(d) This provision is intended to cover not only all violent, predatory and harmful acts, but extends to the full range of prohibitions under penal statutes. It extends to conduct by persons not capable of incurring criminal liability.

**Article 2**

In the performance of their duty, law enforcement officials shall respect and protect human dignity and maintain and uphold the human rights of all persons.

**Commentary :**

(a) The human rights in question are identified and protected by national and international law. Among the relevant international instruments are the Universal

Declaration of Human Rights, the International Covenant on Civil and Political Rights, the Declaration on the Protection of All Persons from Being Subjected to Torture and Other Cruel, Inhuman or Degrading Treatment or Punishment, the United Nations Declaration on the Elimination of All Forms of Racial Discrimination, the International Convention on the Elimination of All Forms of Racial Discrimination, the International Convention on the Suppression and Punishment of the Crime of Apartheid , the Convention on the Prevention and Punishment of the Crime of Genocide, the Standard Minimum Rules for the Treatment of Prisoners and the Vienna Convention on Consular Relations.

(b) National commentaries to this provision should indicate regional or national provisions identifying and protecting these rights.

**Article 3**

Law enforcement officials may use force only when strictly necessary and to the extent required for the performance of their duty.

**Commentary :**

(a) This provision emphasizes that the use of force by law enforcement officials should be exceptional; while it implies that law enforcement officials may be authorized to use force as is reasonably necessary under the circumstances for the prevention of crime or in effecting or assisting in the lawful arrest of offenders or suspected offenders, no force going beyond that may be used.

(b) National law ordinarily restricts the use of force by law enforcement officials in accordance with a principle of proportionality. It is to be understood that such national principles of proportionality are to be respected in the interpretation of this provision. In no case should this provision be interpreted to authorize the use of force which is disproportionate to the legitimate objective to be achieved.

(c) The use of firearms is considered an extreme measure. Every effort should be made to exclude the use of firearms, especially against children. In general, fire-

arms should not be used except when a suspected offender offers armed resistance or otherwise jeopardizes the lives of others and less extreme measures are not sufficient to restrain or apprehend the suspected offender. In every instance in which a firearm is discharged, a report should be made promptly to the competent authorities.

**Article 4**

Matters of a confidential nature in the possession of law enforcement officials shall be kept confidential, unless the performance of duty or the needs of justice strictly require otherwise.

**Commentary :**

By the nature of their duties, law enforcement officials obtain information which may relate to private lives or be potentially harmful to the interests, and especially the reputation, of others. Great care should be exercised in safe-guarding and using such information, which should be disclosed only in the performance

of duty or to serve the needs of justice. Any disclosure of such information for other purposes is wholly improper.

**Article 5**

No law enforcement official may inflict, instigate or tolerate any act of torture or other cruel, inhuman or degrading treatment or punishment, nor may any law enforcement official invoke superior orders or exceptional circumstances such as a state of war or a threat of war, a threat to national security, internal political instability or any other public emergency as a justification of torture or other cruel, inhuman or degrading treatment or punishment.

**Commentary :**

(a) This prohibition derives from the Declaration on the Protection of All Persons from Being Subjected to Torture and Other Cruel, Inhuman or Degrading Treatment or Punishment, adopted by the General Assembly, according to which:

"[Such an act is] an offence to human dignity and shall be condemned as a denial of the purposes of the Charter of the United Nations and as a violation of the human rights and fundamental freedoms proclaimed in the Universal Declaration of Human Rights [and other international human rights instruments]."

(b) The Declaration defines torture as follows:

". . . torture means any act by which severe pain or suffering, whether physical or mental, is intentionally inflicted by or at the instigation of a public official on a person for such purposes as obtaining from him or a third person information or confession, punishing him for an act he has committed or is suspected of having committed, or intimidating him or other persons. It does not include pain or suffering arising only from, inherent in or incidental to, lawful sanctions to the extent consistent with the Standard Minimum Rules for the Treatment of Prisoners."

(c) The term "cruel, inhuman or degrading treatment or punishment" has not been defined by the General Assembly but should be interpreted so as to extend the widest possible protection against abuses, whether physical or mental.

**Article 6**

Law enforcement officials shall ensure the full protection of the health of persons in their custody and, in particular, shall take immediate action to secure medical attention whenever required.

**Commentary :**

(a) "Medical attention", which refers to services rendered by any medical personnel, including certified medical practitioners and paramedics, shall be secured when needed or requested.

(b) While the medical personnel are likely to be attached to the law enforcement operation, law enforcement officials must take into account the judgment of such personnel when

they recommend providing the person in custody with appropriate treatment through, or in consultation with, medical personnel from outside the law enforcement operation.

(c) It is understood that law enforcement officials shall also secure medical attention for victims of violations of law or of accidents occurring in the course of violations of law.

**Article 7**

Law enforcement officials shall not commit any act of corruption. They shall also rigorously oppose and combat all such acts.

**Commentary :**

(a) Any act of corruption, in the same way as any other abuse of authority, is incompatible with the profession of law enforcement officials. The law must be enforced fully with respect to any law enforcement official who commits an act of corruption, as Governments cannot expect to enforce the law among their citizens if they cannot, or will not, enforce the law against their own agents and within their agencies.

(b) While the definition of corruption must be subject to national law, it should be understood to encompass the commission or omission of an act in the performance of or in connection with one's duties, in response to gifts, promises or incentives demanded or accepted, or the wrongful receipt of these once the act has been committed or omitted.

(c) The expression "act of corruption" referred to above should be understood to encompass attempted corruption.

**Article 8**

Law enforcement officials shall respect the law and the present Code. They shall also, to the best of their capability, prevent and rigorously oppose any violations of them.

Law enforcement officials who have reason to believe that a violation of the present Code has occurred or is about to occur shall report the matter to their superior authorities and, where necessary, to other appropriate authorities or organs vested with reviewing or remedial power.

**Commentary :**

(a) This Code shall be observed whenever it has been incorporated into national legislation or practice. If legislation or practice contains stricter provisions than those of the present Code, those stricter provisions shall be observed.

(b) The article seeks to preserve the balance between the need for internal discipline of the agency on which public safety is largely dependent, on the one hand, and the need for dealing with violations of basic human rights, on the other. Law enforcement officials shall report violations within the chain of command and take other lawful action outside the chain of command only when no other remedies are available or effective. It is understood that law enforcement officials shall not suffer administrative or other penalties because they have reported that a violation of this Code has occurred or is about to occur.

(c) The term "appropriate authorities or organs vested with reviewing or remedial power" refers to any authority or organ

existing under national law, whether internal to the law enforcement agency or independent thereof, with statutory, customary or other power to review grievances and complaints arising out of violations within the purview of this Code.

(d) In some countries, the mass media may be regarded as performing complaint review functions similar to those described in subparagraph (c) above. Law enforcement officials may, therefore, be justified if, as a last resort and in accordance with the laws and customs of their own countries and with the provisions of article 4 of the present Code, they bring violations to the attention of public opinion through the mass media.

(e) Law enforcement officials who comply with the provisions of this Code deserve the respect, the full support and the co-operation of the community and of the law enforcement agency in which they serve, as well as the law enforcement profession.

☞☞☞©☜☜☜